# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក—ពេញមួយអាណត្តិ

- បំពេញតួនាទីជាសមាជិកព្រឹទ្ធសភាម្នាក់ក្នុងចំណោមសមាជិកព្រឹទ្ធសភាពីររូបដែលតំណាងឲ្យផលប្រយោជន៍របស់រដ្ឋ California នៅក្នុងសភាសហរដ្ឋអាមេរិក។
- ស្នើ និងបោះឆ្នោតលើច្បាប់ជាតិថ្មី។
- ការបោះឆ្នោតលើការបញ្ជាក់ពីចៅក្រមសហព័ន្ធ ចៅក្រមតុលាការកំពូលរបស់ សហរដ្ឋអាមេរិក និងការតែងតាំងប្រធានាធិបតីកម្រិតខ្ពស់ជាច្រើនចំពោះមុខតំណែងស៊ីវិល និងយោធា។
- នឹងបំពេញតួនាទីអាណត្តិរយៈពេល 6 ឆ្នាំ នៅក្នុងការិយាល័យ ចាប់ផ្តើមនៅថ្ងៃទី 3 ខែមករា ឆ្នាំ 2025។



### Steve Garvey | បក្ស សាធារណរដ្ឋ

ចាប់ពីពេលនោះមក ខ្ញុំបានមកកាន់រដ្ឋ California កាលពី 50 ឆ្នាំមុន ដោយរដ្ឋនេះជាផ្ទះនៅឡើយ។ អស់រយៈពេល 20 ឆ្នាំមកហើយ ខ្ញុំបានលេងឱ្យក្រុមកីឡា Los Angeles Dodgers និង San Diego Padres ។ នៅពេលខ្ញុំចូលលេងក្នុងទីលានប្រគួត ខ្ញុំបានលេងឱ្យអ្នកគាំទ្រទាំងអស់។ មនុស្សគ្រប់រូបមានភាពស្មើគ្នា។ នយោបាយ ពូជសាសន៍ ទំនោរផ្លូវភេទ យេនឌ័រ ហើយនឹងសាវតា មិនបានបែងចែកពួកយើងទេ—ចំណុចទាំងអស់នេះហើយ បាននាំយើងមកជាមួយគ្នា។ រដ្ឋ California ធ្លាប់ជាបេះដូងរបស់អាមេរិក ប៉ុន្តែឥឡូវនេះវាគ្រាន់តែជាការអួរទាំប៉ុណ្ណោះ។ អ្នកនយោបាយអាជីព ផ្តល់ផលប្រយោជន៍ពិសេសនាំមុខសម្រាប់អ្នក និងសុខុមាលភាពគ្រួសាររបស់អ្នក។ យើងមានការគ្មានផ្ទះសម្បែងដែលមិនអាចគ្រប់គ្រងបាន ដោយជំនួសមកវិញដោយលំនៅឋាន។ ជំនួសឱ្យប្រព័ន្ធអន្តោប្រវេសន៍ដែលផ្តល់រង្វាន់ដល់ការខិតខំ យើងមានចលាចលនៅព្រំដែនភាគខាងត្បូង។ ជំនួសឱ្យសង្កាត់ដែលមានសុវត្ថិភាព មានឧក្រិដ្ឋកម្មហិង្សា។ ជំនួសឱ្យតម្លៃសមរម្យ ប្រជាជន California ពិបាកបង់ថ្លៃជួលគ្រឿងទេស និងឧស្ម័ន។ នោះពុំមែនជារដ្ឋ California ដែលយើងស្រឡាញ់នោះទេ។ អ្នក គ្រួសាររបស់អ្នកស័ក្តិសមនឹងទទួលបានអ្វីដែលប្រសើរជាងនេះ។ ខ្ញុំកំពុងត្រឡប់ចូលលេងហ្គេមនេះវិញ ដើម្បីប្រយុទ្ធសម្រាប់រូបអ្នក និងរដ្ឋរបស់ពួកយើង។ ខ្ញុំនឹងធ្វើជាសំឡេងរបស់អ្នកនៅក្នុង Washington, D.C. ជ្រើសរើសសុភវិនិច្ឆ័យលើនយោបាយចាស់កំរិល។ យើងនឹងកាត់បន្ថយភាពគ្មានផ្ទះសម្បែងដោយដោះស្រាយបញ្ហាសុខភាពផ្លូវចិត្ត និង ការញៀនថ្នាំ។ យើងនឹងធានាព្រំដែន និងធ្វើការជាមួយនឹងការអនុវត្តច្បាប់ដើម្បីធ្វើឱ្យសង្កាត់របស់យើងមានសុវត្ថិភាព ហើយនឹងការទទួលខុសត្រូវលើការគ្រប់គ្រងឧក្រិដ្ឋជន។ យើងនឹងកាត់បន្ថយអតិផរណា ដូច្នេះអ្នកអាចចំណាយផ្គត់ផ្គង់ដល់គ្រួសាររបស់អ្នកបាន។ យើងនឹងផ្តល់ឱ្យកូនរបស់ពួកយើងនូវការអប់រំល្អបំផុត។ អ្នកនយោបាយទាំងឡាយធ្វើឲ្យយើងខកចិត្ត។ ខ្ញុំនឹងមិនធ្វើដូច្នោះឡើយ។ នៅពេលដែលប្រជាជន California រួមគ្នាឡើង នោះអ្វីៗគឺអាចធ្វើទៅបាន។ ខ្ញុំបានរស់នៅក្នុងសុបិនរបស់ខ្ញុំ ហើយអ្នកស័ក្តិសមនឹងរស់នៅជាមួយនឹងសុបិនរបស់អ្នកដូចគ្នា។ ក្នុងនាមជាសមាជិកព្រឹទ្ធសភារបស់អ្នក ខ្ញុំនឹងតស៊ូដើម្បីអនាគតរបស់អ្នក និងរដ្ឋ California។

74923 US Hwy. 111, Indian Wells, CA 92210 | អ៊ីម៉ែល៖ Team@SteveGarvey.com | www.SteveGarvey.com
Facebook: Facebook.com/SteveyGarvey6 | X: X.com/SteveyGarvey6 | Instagram: Instagram.com/SteveyGarvey6



### Adam B. Schiff | បក្ស ប្រជាធិបតេយ្យ

Adam Schiff តែងតែតស៊ូយ៉ាងស្វិតស្វាញបំផុត ដើម្បីសម្រេចកិច្ចការទាំងនេះ។ គាត់កំពុងឈរឈ្មោះឱ្យព្រឹទ្ធសភាសហរដ្ឋអាមេរិក ដើម្បីផ្តល់លទ្ធផលសម្រាប់ប្រជាជន California៖ ធ្វើឱ្យលំនៅដ្ឋានកាន់តែមានតម្លៃសមរម្យ កាត់បន្ថយការចំណាយ ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ការការពារសិទ្ធិរំលូតកូន ព្រមទាំងការកសាងសេដ្ឋកិច្ចដែលដំណើរការសម្រាប់មនុស្សគ្រប់គ្នា។ ពីបន្ទប់សវនាការទៅកាន់សភា Adam បានទទួលការគម្រាមកំហែងដ៏ធំបំផុត—ក្រុមហ៊ុនផលិតថ្នាំ អ្នកបំពុល និងក្រុមជួញដូរគ្រឿងញៀន—និងបានឈ្នះ។ លោកបានអនុម័តច្បាប់រាប់សិបដើម្បីបញ្ចុះថ្លៃថ្នាំតាមវេជ្ជបញ្ជា ពង្រីកមធ្យោបាយដឹកជញ្ជូនសាធារណៈ បង្កើតការងារ ធ្វើឱ្យមនុស្សចេញពីដងផ្លូវ នាំយកសៀវភៅសិក្សាថ្មីៗមកសាលារបស់យើង បង្កើតប្រព័ន្ធព្រមានជាមុនអំពីគ្រោះរញ្ជួយដី និងបង្កើតច្បាប់ស្តីពីកម្រងសិទ្ធិអ្នកជម្ងឺនៅរដ្ឋ California។ ហើយនៅពេលដែលលទ្ធិប្រជាធិបតេយ្យរបស់យើង ស្ថិតនៅក្រោមការរំលោភបំពានដោយប្រធានាធិបតីដ៏គ្រោះថ្នាក់ Adam បានស៊ើបអង្កេតចោទប្រកាន់ និងឱ្យគាត់ទទួលខុសត្រូវចំពោះការញុះញង់ឱ្យមានការបះបោរ។ Adam នឹងធ្វើការជាមួយគណបក្សប្រជាធិបតេយ្យ សាធារណរដ្ឋ និងឯករាជ្យដើម្បីធ្វើឱ្យវាមានលទ្ធភាពក្នុងការចិញ្ចឹមគ្រួសារនៅរដ្ឋ California ម្តងទៀត។ របៀបវារៈស្តីពីលទ្ធភាពទិញបានរបស់គាត់អំពាវនាវឱ្យមានការថែទាំសុខភាពជាសកល និងការថែទាំកុមារ ព្រមទាំងបង្កើនការវិនិយោគនៅក្នុងសន្តិសុខសង្គម។ គាត់នឹងទទួលយកអ្នកអភិវឌ្ឍន៍ធំៗ និងអ្នកវិនិយោគបរទេសដែលជំរុញតម្លៃផ្ទះ ព្រមទាំងសាជីវកម្មធំៗដែលកំពុងទាញផលកេងចំណេញពីអ្នកប្រើប្រាស់ នៅក្នុងទំហំទឹកប្រាក់រាប់ពាន់លានដុល្លារ។ Adam បានធំឡើងនៅ Bay Area ហើយលោកកំពុងធ្វើការនៅរដូវក្តៅនៅក្នុងទីធ្លាហាងឈើរបស់ឪពុកលោក ហើយលោកក៏ជាអ្នកពន្លត់អគ្គីភ័យតាមរដូវកាល។ បន្ទាប់ពីចប់សាលាច្បាប់ គាត់បានតាំងទីលំនៅនៅរដ្ឋ California ភាគខាងត្បូង ហើយបានជួបស្នេហារបស់គាត់ Eve—ក៏យល់ព្រម ពួកគេគឺ Adam និង Eve! ពួកគេបានរៀបការអស់រយៈពេល 29 ឆ្នាំហើយមានកូនដ៏អស្ចារ្យពីរនាក់។ សូមចូលទៅ *www.AdamSchiff.com* ដើម្បីឈ្វេងយល់បន្ថែម។

135 E. Olive Ave., Box 750, Burbank, CA 91502 | ទូរសព្ទ៖ (818) 841-2828 | អ៊ីម៉ែល៖ contact@adamschiff.com
www.adamschiff.com | Facebook: www.facebook.com/AdamSchiffCA | X: www.twitter.com/adamschiffca
Instagram: www.instagram.com/adamschiffca/ | www.threads.net/@adamschiffca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជារបស់ខ្លួនគេផ្ទាល់ ហើយមិនតំណាងឲ្យទស្សនៈ និងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការទេ។ លំដាប់នៃសេចក្តីថ្លែងការណ៍ ត្រូវបានកំណត់តាមការជ្រើសរើសដោយព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យអំពីភាពត្រឹមត្រូវដោយទីភ្នាក់ងារផ្លូវការណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានដាក់ស្នើមកតាមការស្ម័គ្រចិត្ត និងបង់ប្រាក់ដោយបេក្ខជន។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក—ពាក់កណ្តាលអាណត្តិ/មិនទាន់ផុតកំណត់

- បំពេញតួនាទីជាសមាជិកព្រឹទ្ធសភាម្នាក់ក្នុងចំណោមសមាជិកព្រឹទ្ធសភាពីររូបដែលតំណាងឲ្យផលប្រយោជន៍របស់រដ្ឋ California នៅក្នុងសភាសហរដ្ឋអាមេរិក។
- ស្នើ និងបោះឆ្នោតលើច្បាប់ជាតិថ្មី។
- ការបោះឆ្នោតលើការបញ្ជាក់ពីចៅក្រមសហព័ន្ធ ចៅក្រមតុលាការកំពូលរបស់ សហរដ្ឋអាមេរិក និងការតែងតាំងប្រធានាធិបតីកម្រិតខ្ពស់ជាច្រើនចំពោះមុខតំណែងស៊ីវិល និងយោធា។
- នឹងបំពេញតួនាទីសម្រាប់អាណត្តិបច្ចុប្បន្នដែលនៅសល់ ហើយបញ្ចប់នៅថ្ងៃទី 3 ខែមករា ឆ្នាំ 2025។



### Steve Garvey | បក្ស សាធារណរដ្ឋ

អស់រយៈពេលជាង 50 ឆ្នាំមកហើយ ខ្ញុំបានមកកាន់រដ្ឋ California ជាលើកដំបូង។ 20 ឆ្នាំក្រោយមក ខ្ញុំបានលេងឱ្យក្រុមកីឡា Los Angeles Dodgers ហើយនឹង San Diego Padres នៅចំពោះមុខអ្នកគាំទ្ររាប់លាននាក់ដែលកំពុងមើលតាមទូរទស្សន៍ និងអបអរសាទរនៅលើកន្លែងឈរ។ នៅពេលនោះ រដ្ឋ California គឺជាចង្វាក់បេះដូងរបស់អាមេរិក ប៉ុន្តែឥឡូវនេះវាគ្រាន់តែជាការរស្សូររហឹមតិចៗប៉ុណ្ណោះ។ គោលនយោបាយមិនល្អជាច្រើនឆ្នាំបាននាំឱ្យតម្លៃនៃការរស់នៅកើនឡើងខ្ពស់បំផុតនៅក្នុងប្រទេស ភាពវឹកវរនៅព្រំដែនខាងត្បូង ការកើនឡើងនៃប្រើអំពើហឹង្សា ភាពគ្មានផ្ទះសម្បែងដែលមានភាពច្របូកច្របល់ និងការរៀនសូត្រមិនល្អសាលារៀន។ អ្នកនយោបាយបានធ្វើឱ្យប្រជាជន California ទាំងអស់ធ្លាក់ចុះអាប់ឱន។ នៅពេលដែលខ្ញុំជាសមាជិកព្រឹទ្ធសភារបស់អ្នក យើងនឹងចាប់ផ្តើមពិនិត្យរកដំណោះស្រាយភាពគ្មានផ្ទះសម្បែងដោយម៉ត់ចត់ទៅលើផ្នែកសុខភាពផ្លូវចិត្ត ការព្យាបាលការញៀនថ្នាំ និងតម្លៃផ្ទះសម្បែង។ យើងនឹងធានាព្រំដែន ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម ពង្រឹងច្បាប់របស់យើង ព្រមទាំងដាក់ទោសឧក្រិដ្ឋជន។ យើងនឹងមានសាលារៀនល្អបំផុតនៅក្នុងប្រទេសសាជាថ្មី ហើយអាចផ្តល់ឱ្យកូនរបស់យើចូលរៀនអប់រំថ្នាក់ដំបូងបាន។ យើងនឹងបង្កើតការងារល្អៗ គាំទ្រម្ចាស់អាជីវកម្មខ្នាតតូច និងកាត់បន្ថយថ្លៃនៅក្នុងការរស់នៅ ដូច្នេះគ្រួសាររបស់អ្នកនឹងសន្សំបានប្រាក់ច្រើន។ យើងនឹងដោះស្រាយរួមគ្នានូវបញ្ហារបស់យើង ជាមួយនឹងដំណោះស្រាយសមហេតុផល មិនមែនដូចនយោបាយមុនៗនោះទេ។ វាដល់ពេលហើយសម្រាប់ភាពក្លាហានផ្នែកនយោបាយ ហើយយើងសមនឹងទទួលបានអ្នកដឹកនាំដែលនឹងតំណាងឱ្យផលប្រយោជន៍របស់អ្នក មិនមែនបម្រើឱ្យប្រយោជន៍តែខ្លួនពួកគេនោះទេ។ រដ្ឋ California បានអនុញ្ញាតឱ្យខ្ញុំរស់នៅក្នុងក្តីសុបិនរបស់ខ្ញុំក្នុងការលេងនៅ Major Leagues ហើយអ្នកសមនឹងទទួលបានវាដូច្នេះដែរ។ ខ្ញុំសង្ឃឹមថានឹងទទួលបានការគាំទ្ររបស់អ្នក ដូច្នេះយើងអាចធ្វើការរួមគ្នា ហើយនឹងស្តារគុណភាពជីវិត និងឱកាសដែលយើងទាំងអស់គ្នាសមនឹងទទួលបាន។

74923 US Hwy. 111, Indian Wells, CA 92210 | អ៊ីម៉ែល៖ Team@SteveGarvey.com | www.SteveGarvey.com
Facebook: Facebook.com/SteveyGarvey6 | X: X.com/SteveyGarvey6 | Instagram: Instagram.com/SteveyGarvey6



### Adam B. Schiff | បក្ស ប្រជាធិបតេយ្យ

Adam Schiff តែងតែតស៊ូយ៉ាងស្វិតស្វាញបំផុត ដើម្បីសម្រេចកិច្ចការទាំងនេះ។ គាត់កំពុងឈរឈ្មោះឱ្យព្រឹទ្ធសភាសហរដ្ឋអាមេរិក ដើម្បីផ្តល់លទ្ធផលសម្រាប់ប្រជាជន California៖ ធ្វើឱ្យលំនៅដ្ឋានកាន់តែមានតម្លៃសមរម្យ កាត់បន្ថយការចំណាយ ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ការការពារសិទ្ធិរំលូតកូន ព្រមទាំងការកសាងសេដ្ឋកិច្ចដែលដំណើរការសម្រាប់មនុស្សគ្រប់គ្នា។ ពីបន្ទប់សវនាការទៅកាន់សភា Adam បានទទួលការគម្រាមកំហែងដ៏ធំបំផុត—ក្រុមហ៊ុនផលិតថ្នាំ អ្នកបំពុល និងក្រុមជួញដូរគ្រឿងញៀន—និងបានឈ្នះ។ លោកបានអនុម័តច្បាប់រាប់សិបដើម្បីបញ្ចុះថ្លៃថ្នាំតាមវេជ្ជបញ្ជា ពង្រីកមធ្យោបាយដឹកជញ្ជូនសាធារណៈ បង្កើតការងារ ធ្វើឱ្យមនុស្សចេញពីដងផ្លូវ នាំយកសៀវភៅសិក្សាថ្មីៗមកសាលារបស់យើង បង្កើតប្រព័ន្ធព្រមានជាមុនអំពីគ្រោះរញ្ជួយដី និងបង្កើតច្បាប់ស្តីពីកម្រងសិទ្ធិអ្នកជម្ងឺនៅរដ្ឋ California។ ហើយនៅពេលដែលលទ្ធិប្រជាធិបតេយ្យរបស់យើង ស្ថិតនៅក្រោមការរំលោភបំពានដោយប្រធានាធិបតីដ៏គ្រោះថ្នាក់ Adam បានស៊ើបអង្កេតចោទប្រកាន់ និងឱ្យគាត់ទទួលខុសត្រូវចំពោះការញុះញង់ឱ្យមានការបះបោរ។ Adam នឹងធ្វើការជាមួយគណបក្សប្រជាធិបតេយ្យ សាធារណរដ្ឋ និងឯករាជ្យដើម្បីធ្វើឱ្យវាមានលទ្ធភាពក្នុងការចិញ្ចឹមគ្រួសារនៅរដ្ឋ California ម្តងទៀត។ របៀបវារៈស្តីពីលទ្ធភាពទិញបានរបស់គាត់អំពាវនាវឱ្យមានការថែទាំសុខភាពជាសកល និងការថែទាំកុមារ ព្រមទាំងបង្កើនការវិនិយោគនៅក្នុងសន្តិសុខសង្គម។ គាត់នឹងទទួលយកអ្នកអភិវឌ្ឍន៍ធំៗ និងអ្នកវិនិយោគបរទេសដែលជំរុញតម្លៃផ្ទះ ព្រមទាំងសាជីវកម្មធំៗដែលកំពុងទាញឆក់អ្នកប្រើប្រាស់ នៅក្នុងទំហំទឹកប្រាក់រាប់ពាន់លានដុល្លារ។ Adam បានធំឡើងនៅ Bay Area ហើយលោកកំពុងធ្វើការនៅរដូវក្តៅនៅក្នុងទីធ្លាហាងឈើរបស់ឪពុកលោក ហើយលោកក៏ជាអ្នកពន្លត់អគ្គីភ័យតាមរដូវកាល។ បន្ទាប់ពីចប់សាលាច្បាប់ គាត់បានតាំងទីលំនៅនៅរដ្ឋ California ភាគខាងត្បូង ហើយបានជួបស្នេហារបស់គាត់ Eve—ក៏យល់ព្រម ពួកគេគឺ Adam និង Eve! ពួកគេបានរៀបការអស់រយៈពេល 29 ឆ្នាំហើយមានកូនដ៏អស្ចារ្យពីរនាក់។ សូមចូលទៅ *www.AdamSchiff.com* ដើម្បីឈ្វេងយល់បន្ថែម។

135 E. Olive Ave., Box 750, Burbank, CA 91502 | ទូរសព្ទ៖ (818) 841-2828 | អ៊ីម៉ែល៖ contact@adamschiff.com
www.adamschiff.com | Facebook: www.facebook.com/AdamSchiffCA | X: www.twitter.com/adamschiffca
Instagram: www.instagram.com/adamschiffca/ | www.threads.net/@adamschiffca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជារបស់ខ្លួនគេផ្ទាល់ ហើយមិនតំណាងឲ្យទស្សនៈ និងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការទេ។ លំដាប់នៃសេចក្តីថ្លែងការណ៍ ត្រូវបានកំណត់តាមការជ្រើសរើសដោយព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យអំពីភាពត្រឹមត្រូវដោយទីភ្នាក់ងារផ្លូវការណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានដាក់ស្នើមកតាមការស្ម័គ្រចិត្ត និងបង់ប្រាក់ដោយបេក្ខជន។